ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ: 012 សគបយ

ភ្នំពេញ. ថ្ងៃទី 02 ខែមិថុនា ឆ្នាំ២០០០

## សារាចរ

## ស្តីពី

## ការអនុវត្តន៍វិធានការអនាម័យ និងសន្តិសុខការងារ

## នៅតាមគ្រឹះស្ថានផលិតកម្ម

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាសង្កេតឃើញថា នៅតាមគ្រឹះស្ថានផលិតកម្មនានា ការអនុវត្តន៍វិធានការអនាម័យនិងសន្តិសុខការងារ នៅមានការខ្វះខាតគួរអោយព្រួយបារម្ភហើយ ។ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមផ្តល់នូវការណែនាំជាជំហានដំបូងសំដៅធ្វើអោយ ការអនុវត្តន៍វិធានការ អនាម័យ និងសន្តិសុខការងារទាំងនោះ អោយបានប្រសើរឡើងដើម្បីធានាផលប្រយោជន៍ស្របច្បាប់ដល់គ្រប់ភាគី ដូចតទៅ :-

១-ត្រូវរៀបចំកន្លែងពុះអុសអោយនៅឆ្ងាយពីច្រកចេញចូលនិងឆ្ងាយពីកន្លែងធ្វើការផ្សេងទៀត ហើយត្រូវហាមមិនអោយក្មេងទៅក្បែរកន្លែងនោះទេ ។

២-ចំពោះគ្រឹះស្ថាន ដែលមានប្រើម៉ាស៊ីនអារអុសត្រូវធ្វើគំរបខ្សែពានម៉ាស៊ីនអារអុសអោយបានរឹងមាំហើយត្រូវរៀបចំអោយកម្មករអារអុសឈរសងខាងកន្ទុយអុសពេលគឺហាមឈរទល់មុខផ្លែរណារ ។

៣-ចំពោះគ្រឹះស្ថានផលិតឥដ្ឋដែលប្រើអុសនិងអង្កាម ត្រូវសាងសង់រោងម៉ាស៊ីនផលិតឥដ្ឋអោយបានរឹងមាំនិងប្រក់ដំបូលអោយបានជិត ។

៤-ចំពោះការប្រើម៉ាស៊ីនកិនដីផលិតឥដ្ឋដោយប្រើធ្នើ ត្រូវសាងសង់អោយបានរឹងមាំ ទាំងធ្នើទាំងសសរទ្រធ្នើ ។ ទំងន់ដីដែលដាក់លើធ្នើ ត្រូវអោយសមាមាត្រជាមួយនិងធ្នើ ។ កម្មករដែលធ្វើការនៅទីនោះមិនត្រូវអោយឡើងអង្គុយលើធ្នើដើម្បីកាប់ដីញាត់ចូលប្រហោងប្រដាប់កិនដីទេពេលគឺកម្មករត្រូវឈរសងខាងធ្នើ

ដើម្បីកាប់ដីញាត់ចូលប្រហោងកិនដី ដោយមិនត្រូវប្រើដៃឬជើងលូកចូលក្នុងប្រហោងកិនដីទេ ។ ខ្សែពានម៉ាស៊ីនកិនដីត្រូវមានគំរបការពាររឹងមាំ ។

៥-ចំពោះការប្រើប្រាស់ម៉ាស៊ីនកិនដីដោយគ្មានប្រើធ្មើ ត្រូវសាងសង់រោងអោយបានគង់វង់សំរាប់កម្មករបានធ្វើការក្នុងម្លប់ ។ គ្រឿងយន្តកិនដីផលិតឥដ្ឋនៅត្រូវមានគំរបការពារនិងគំរបការពារខ្សែពានអោយបានរឹងមាំ ។កម្មករដែលធ្វើការនៅទីនោះ មិនត្រូវយកដៃលូកចូលក្នុងប្រហោងប្រដាប់កិនដីដើម្បីសង្កត់ដីទេ ត្រូវប្រើឧបករណ៍ផ្សេងសំរាប់បុកដីបញ្ចូលក្នុងប្រហោងនោះវិញ ។

៦-ត្រូវរៀបចំបណ្តាញអគ្គីសនីអោយបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសអគ្គីសនី ដោយរៀបចំអោយមានប្រអប់សំរាប់ដាក់កុងតាក់បិទបើកចរន្តអគ្គីសនី និងគំរប ការពារកុងតាក់អោយបានត្រឹមត្រូវ ។

៧-ចំពោះគ្រឹះស្ថានដែលមានប្រើម៉ាស៊ីនភ្លើង ត្រូវផ្លាស់ប្តូរបំពង់ផ្សែងម៉ាស៊ីន ដែលពុកធ្លុះធ្លាយចេញជាប្រចាំ ។ ត្រូវរៀបចំធុងទឹកម៉ាស៊ីនអោយនៅក្រៅជញ្ជាំងរោងម៉ាស៊ីនភ្លើងហើយមិនត្រូវស្តុកទុកប្រេងម៉ាស៊ូត ឬប្រេងម៉ាស៊ីននៅក្នុងរោងម៉ាស៊ីនភ្លើងទេ ពោលគឺត្រូវទុកដាក់ប្រេងទាំងនេះនៅទីកន្លែងផ្សេង ។

៨-ចំពោះកម្មករដែលធ្វើការនៅឡដុតឥដ្ឋ ត្រូវមានសំភារៈការពារពលកម្មដូចជា សំលៀកបំពាក់ក្រាស់ ស្រោមដៃក្រណាត់ក្រាស់ ស្បែកជើងក្រណាត់ ឬស្បែក " កវែង" មួកនិងវ៉ែនតាខ្មៅជាដើម ។

៩-ចំពោះការប្រើប្រាស់កម្មករ និយោជិត ដែលមានអាយុពី ១៥ ទៅក្រោម ១៨ឆ្នាំ ត្រូវធានាថាការងារនោះ មិនបណ្តាលអោយប៉ះពាល់ដល់ សុខភាព សន្តិសុខ ឬសីលធម៌របស់មនុស្សពេញវ័យ ដោយសារតែលក្ខខណ្ឌ ឬប្រភេទរបស់មុខរបរ និងការងារទាំងនោះបង្កឡើង ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថាអស់លោក លោកស្រីជាម្ចាស់ និងនាយកគ្រឹះស្ថានផលិតឥដ្ឋទាំងអស់ច្បាស់ជាយកចិត្តទុកដាក់អនុវត្តតាមការណែនាំខាងលើបានល្អប្រសើរជាពុំខាន ។៕

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

អ៊ិត សំហេង

**ចម្លងជូន**

-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត- ក្រុង "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក "ដើម្បីជ្រាប"
-សហភាពសហជីព "ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និង ឯកសារ